ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..០០៧.........សហវ.......

## សារាចរណែនាំ

## ស្តីពី

## ការពន្យារពេលការអនុវត្តការពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងអនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងក្នុងគោលបំណងទុកលទ្ធភាពនិងពេលវេលាឱ្យបានសមស្របដល់វិស័យឯកជនក្នុងការរៀបចំខ្លួនដើម្បីអនុវត្តច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចខាងក្រោម÷

១- ពន្យារពេលអនុវត្តអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ចំពោះតែសហគ្រាស ឬនីតិបុគ្គល ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម និង/ឬនៅអគ្គនាយកដ្ឋានពន្ធដារជាសហគ្រាសអ្នកជាប់ពន្ធធំ និងសហគ្រាសអ្នកជាប់ពន្ធមធ្យម និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលបានចុះបញ្ជីនៅក្រសួង និងស្ថាប័នជំនាញ រយៈពេល ១ (មួយ) ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទចេញសារាចរណែនាំនេះ តទៅ។ ការពន្យារនេះមិនអនុវត្តចំពោះគណនេយ្យករ និងសវនករដែលជាសមាជិករបស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា និងទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និង/ឬសវនកម្មពី **ក.ជ.គ.** ឡើយ។

២- ក្នុងរយៈពេលអនុគ្រោះនេះ សហគ្រាស ឬនីតិបុគ្គល ដែលទទួលបានការពន្យារតាមសារាចរណែនាំនេះត្រូវរៀបចំខ្លួនឱ្យបានរួចរាល់ ដើម្បីត្រៀមលក្ខណៈក្នុងការអនុវត្តច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ឱ្យមានប្រសិទ្ធភាព និងសក្តិសិទ្ធភាព។

៣- ក្រុមប្រឹក្សាជាតិគណនេយ្យ និងអគ្គនាយកដ្ឋានពន្ធដារ ត្រូវសហការគ្នាយ៉ាងជិតស្និទ្ធ ដើម្បីផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ព្រមទាំងរៀបចំការបណ្តុះបណ្តាលដល់សហគ្រាសអំពីការកាន់បញ្ជីគណនេយ្យ និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមតាមស្តង់ដាគណនេយ្យជាធរមាន ឱ្យទទួលបានលទ្ធផលល្អប្រសើរបន្ថែមទៀត។

ទទួលបានសារាចរណែនាំនេះ ក្រុមប្រឹក្សាជាតិគណនេយ្យ អគ្គនាយកដ្ឋានពន្ធដារ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ថាប័នពាក់ព័ន្ធ សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវសហការអនុវត្តឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ៩រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

<u>កន្លែងទទួល ៖</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ